ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ...................................................

# សុន្ទរកថា

## លោកជំទាវ ជា សិរី អគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីផ្សព្វផ្សាយច្បាប់ស្តីពី " ស្ថិតិ "
## សហការរៀបចំដោយ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា
## នៅសណ្ឋាគារភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦

**សូមគោរព**!

- ឯកឧត្តម **សន ស៊ីថន** រដ្ឋលេខាធិការ ក្រសួងផែនការ
- ឯកឧត្តម **ទួន ថវរៈ** រដ្ឋលេខាធិការ ក្រសួងផែនការ
- ឯកឧត្តម **ប៉ាន ម៉ុនធឿន** រដ្ឋលេខាធិការ ក្រសួងផែនការ
- ឯកឧត្តម **ហោ ដារិទ្ធ** អនុរដ្ឋលេខាធិការ ក្រសួងផែនការ
- លោកជំទាវ **ដួង សារុន** អនុរដ្ឋលេខាធិការ ក្រសួងផែនការ
- លោកជំទាវ **ហាង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញា ជាទីមេត្រី !

ក្នុងនាមធនាគារជាតិនៃកម្ពុជា និងក្នុងនាមរូបនាងខ្ញុំផ្ទាល់ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងមានសេចក្តីសោមនស្សរីករាយបំផុតដោយបានចូលរួមជាគណៈអធិបតី ក្នុងពិធីផ្សព្វផ្សាយច្បាប់ស្តីពី " ស្ថិតិ " នាពេលនេះ ។ នាងខ្ញុំសូមចូលរួមអបអរសាទរ និងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ សម្រាប់សមិទ្ធផលថ្មីនេះ ដូច **លោកជំទាវ ប្រតិភូ** បានជម្រាបជូនអង្គពិធីទាំងមូលនាពេលមុននេះ ។

ការធ្វើបច្ចុប្បន្នកម្ម ឬវិសោធនកម្មនៃច្បាប់ស្តីពី " ស្ថិតិ " បានសបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលមកលើវិស័យស្ថិតិជាតិ តាមរយៈការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ដំណើរការប្រមូល និងផ្សព្វផ្សាយទិន្នន័យ ការបង្កើតយន្តការជួយសម្រួលដល់ការប្រមូលទិន្នន័យ និងជម្រុញឲ្យមានកិច្ចសហការពីគ្រប់មជ្ឈដ្ឋានទាំងអស់ ក្នុងនោះរួមមាន ការបង្កើតក្រុមប្រឹក្សាស្ថិតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង ជាដើម ។ ស្ថិតិមួយដែលប្រកបដោយគុណភាព និងផ្សព្វផ្សាយទាន់ពេលវេលា អាចជួយសម្រួលដល់អ្នកប្រើប្រាស់ទិន្នន័យ ដូចជារាជរដ្ឋាភិបាល អ្នកសិក្សាស្រាវជ្រាវ ធុរជន អង្គការអន្តរជាតិ និងអ្នកប្រើប្រាស់ទិន្នន័យផ្សេងទៀត អាចមាន



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

លទ្ធភាពគ្រប់គ្រាន់ក្នុងការរៀបចំ ឬកែតម្រូវគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់ខ្លួនឲ្យបានត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាព ។

ជាមួយគ្នានេះ ក្នុងនាមជាអ្នកចងក្រងស្ថិតិម៉ាក្រូសេដ្ឋកិច្ចចម្បងៗពីរ និងស្ថិតិហិរញ្ញវត្ថុផ្សេងទៀត ដែលក្នុងនោះរួមមាន ស្ថិតិវិស័យក្រៅប្រទេស (External Sector Statistics) និងស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ (Monetary and Financial Statistics) ជាដើម ។ ធនាគារជាតិនៃកម្ពុជាបានខិតខំប្រឹងប្រែងក្នុងការចងក្រង និងផ្សព្វផ្សាយជាប្រចាំទាំងក្នុងព្រឹត្តិបត្រ និងគេហទំព័ររបស់ខ្លួន ។ ទន្ទឹមនេះ គុណភាពស្ថិតិ គឺជាចំណុចអាទិភាពមួយដែលធនាគារជាតិនៃកម្ពុជាតែងតែយកចិត្តទុកដាក់ខ្ពស់ តាមរយៈការធ្វើបច្ចុប្បន្នកម្មលើវិធីសាស្ត្រចងក្រង ការពង្រីកវិសាលភាពរបស់ប្រភពទិន្នន័យ និងការកែលម្អវិធីសាស្ត្រនៃការប្រមូលទិន្នន័យ ។ ក្នុងក្របខណ្ឌនៃការផ្លាស់ប្តូរទិន្នន័យ និងកិច្ចសហការអន្តរក្រសួង ធនាគារជាតិនៃកម្ពុជាតែងតែផ្តល់នូវទិន្នន័យស្ថិតិ និងកិច្ចសហការល្អជាមួយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងបណ្តាក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ក្នុងគោលដៅធ្វើឲ្យប្រសើរឡើងនូវគុណភាពទិន្នន័យ និងភាពស៊ីគ្នានៃព័ត៌មានស្ថិតិ ។

*ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញា ជាទីមេត្រី!*

គួររំលឹកផងដែរថា រយៈពេលកន្លងទៅថ្មីៗនេះ ក្នុងកិច្ចការពង្រឹង និងពង្រីកគុណភាពស្ថិតិ ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ បានសហការគ្នាធ្វើការអង្កេតរួមមួយជាលើកដំបូងស្តីពី " **ការវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៤** " ។ កិច្ចសហការដ៏ជិតស្និទ្ធនេះ បានធ្វើឲ្យយើងទទួលបាននូវលទ្ធផលប្រកបដោយជោគជ័យ និងគួរជាទីពេញចិត្ត ។ គោលបំណងដែលធនាគារជាតិនៃកម្ពុជាបានសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ធ្វើការអង្កេតនេះឡើង គឺដោយសារតែយើងមើលឃើញថា កង្វះខាតទិន្នន័យស្ថិតិវិនិយោគផ្ទាល់បរទេសគឺជាឧបសគ្គចម្បងមួយរបស់រដ្ឋាភិបាល និងវិស័យឯកជន ក្នុងការវិភាគឲ្យបានស៊ីជម្រៅអំពីវិនិយោគបរទេស ។ វិនិយោគិនត្រូវការស្ថិតិនេះ ដើម្បីពិនិត្យពីវិស័យសក្តានុពលក្នុងសេដ្ឋកិច្ច ទំហំទឹកប្រាក់ដែលបានវិនិយោគ និងលទ្ធភាពរកចំណេញពីវិស័យទាំងនោះ ស្របពេលដែលរាជរដ្ឋាភិបាលអាចប្រើប្រាស់ព័ត៌មាននេះ ដើម្បីរៀបចំផែនការគៀរគរការវិនិយោគ ការបែងចែកធនធានបន្ថែមលើវិស័យអាទិភាព និងការកែលម្អនយោបាយលើកទឹកចិត្តចំពោះវិនិយោគិន ក្នុងគោលដៅរក្សាកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស ។ ការអង្កេត គឺផ្តោតលើការប្រមូលទិន្នន័យអំពីតម្លៃនៃស្ថានភាពចុងគ្រា នៃការវិនិយោគផ្ទាល់បរទេសឆ្នាំ២០១៤ ក៏ដូចជាចរិតលក្ខណៈប្រតិបត្តិការនៃក្រុមហ៊ុន-សហគ្រាសដែលត្រូវបានកាន់កាប់ដោយបរទេសក្នុងប្រទេសកម្ពុជា ។ល។ ទោះបីជាត្រូវបានផ្តល់សិទ្ធិពេញលេញតាមផ្លូវច្បាប់លើការអង្កេតក៏ដោយ ក៏ដំណើរការនៃការប្រមូលទិន្នន័យនៅតែជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ផងដែរ ។ កិច្ចសហការរបស់អ្នកឆ្លើយតបមិនពេញលេញ និងបដិសេធ គឺនៅមានកម្រិតខ្ពស់ បើធៀបជាមួយនឹងអ្នកឆ្លើយតបពេញលេញ នៃចំនួនសហគ្រាសដែលបានធ្វើការអង្កេតទាំងអស់ ដោយចំនួនសរុបនៃសហគ្រាសដែលត្រូវបានជ្រើសរើសធ្វើជាសំណាកគំរូគឺមានចំនួន ១២៤ សហគ្រាស ។ ដំណើរការនៃការអង្កេតត្រូវបានពន្យារពេលដោយសារមន្ត្រីសម្ភាសន៍មួយចំនួនត្រូវធ្វើដំណើរជាច្រើនលើកច្រើនសារទៅតាមទីតាំងសហគ្រាសនៃអ្នកឆ្លើយតប ដើម្បីប្រមូលកម្រងសំណួរដែលបានឆ្លើយតប

ពេញលេញ ឬឆ្លើយតបមិនពេញលេញទាំងនោះ ។ ចំពោះលទ្ធផលនៃការអង្កេត ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ បានសហការគ្នារៀបចំពិធីប្រកាសផ្សព្វផ្សាយជាផ្លូវការក្នុងខែកក្កដា និងបោះពុម្ពផ្សាយក្នុងខែកញ្ញា ឆ្នាំ២០១៦ កន្លងទៅថ្មីៗនេះ រួចរាល់ហើយ ។ នាងខ្ញុំជឿជាក់ថា លទ្ធផលនៃការអង្កេតនឹងត្រូវបានប្រើប្រាស់ជាធាតុចូលមួយផ្នែកយ៉ាងសំខាន់ សម្រាប់ឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការឥតឈប់ឈរនៃការប្រើប្រាស់ទិន្នន័យស្ថិតិ ស្របតាមបរិបទនៃសាកលភាវូបនីយកម្ម និងការរីកចម្រើនឥតឈប់ឈរនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន ។ ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ នឹងបន្តពង្រឹងកិច្ចសហការដ៏ល្អជាប្រពៃណី ដើម្បីជួយធ្វើឲ្យប្រសើរឡើងនូវគុណភាពស្ថិតិកម្ពុជា និងប្រព័ន្ធស្ថិតិជាតិទាំងមូល ។

ជាថ្មីម្តងទៀត ក្នុងនាមធនាគារជាតិនៃកម្ពុជា និងក្នុងនាមរូបនាងខ្ញុំផ្ទាល់ នាងខ្ញុំសូមឆ្លៀតយកឱកាសដ៏ថ្លៃថ្លានេះ ដើម្បីថ្លែងអំណរគុណដល់ភាគីពាក់ព័ន្ធទាំងអស់ រួមមាន ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័នឯកជន និងស្ថាប័នអន្តរជាតិ ដែលបានផ្តល់កិច្ចសហការយ៉ាងល្អកន្លងមកក្នុងការផ្តល់ទិន្នន័យជូនធនាគារជាតិនៃកម្ពុជាក្នុងគោលបំណងដើម្បីជំរុញស្ថិតិម៉ាក្រូសេដ្ឋកិច្ចសំខាន់ទាំងពីរ ដូចបានជម្រាបជូនខាងលើ ។ ជាមួយគ្នានេះផងដែរ នាងខ្ញុំសូមស្នើសុំដោយទទូចដល់ភាគីពាក់ព័ន្ធទាំងអស់ មេត្តាចូលរួម និងសហការអនុវត្តច្បាប់ថ្មីស្តីពី " ស្ថិតិ " នេះឲ្យបានសកម្ម និងមានប្រសិទ្ធភាពខ្ពស់បំផុត ។

ជាទីបញ្ចប់ នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះ **ឯកឧត្តម ឆាយថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួងផែនការ និងថ្នាក់ដឹកនាំទាំងអស់ និង **ឯកឧត្តម ជា ចាន់តូ** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា និងថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាទាំងអស់ ដែលតែងតែផ្តល់ការឧបត្ថម្ភគាំទ្រ និងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាលើវិស័យស្ថិតិកម្ពុជា ជាពិសេសគឺស្ថិតិក្រៅប្រទេស និងស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ ។ ទន្ទឹមនេះ នាងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ាលោក លោកស្រី និងអ្នកនាងកញ្ញាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងពិធីផ្សព្វផ្សាយច្បាប់ថ្មីស្តីពី " ស្ថិតិ " នាថ្ងៃនេះ ។

នាងខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញាទាំងអស់ ឲ្យជួបប្រទះនូវពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**